ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥

នៅក្នុងខែតុលា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម រួមមាន៖**
  - ❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៤លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖

    ១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់ ស្តីពី៖
    - ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន។
    - ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់រូបវន្តបុគ្គល។
    - ការអនុម័តយល់ព្រមលើពិធីសារទីមួយធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន។
    - ការអនុម័តយល់ព្រមលើពិធីសារទីពីរធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ និង
    - ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

២- ពិនិត្យ និងសម្រេចសំណើរបស់គណៈកម្មការពិសេស លើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៣- ពិនិត្យ និងសម្រេចលើរបាយការណ៍សង្ខេបស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ នីតិកាលទី៥ និង

៤- កំណត់កាលបរិច្ឆេទ របៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥។

❖ បើកសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖

១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់ ដូចខាងលើ និង

២- ស្តាប់របាយការណ៍សង្ខេបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ នីតិកាលទី៥។

❖ ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ អាណត្តិទី៤ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព) លើកទី៣ អាណត្តិទី៤ ស្តីពី កំណត់ហេតុប្រជុំ (ក.ជ.ប.ព) លើកទី២ និងសកម្មភាពការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយប្រចាំខែតុលា ឆ្នាំ២០២៥ នៅសាលប្រជុំធំ អង្គភាពប្រឆាំងអំពើពុករលួយ។

## ២-មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយ៖ ១/វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២/វិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន ៣/វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ និង ៤/វិទ្យាស្ថានអភិបាលកិច្ចឌីជីថលនៃបណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ដើម្បីស្វែងយល់អំពីវឌ្ឍនភាពវិទ្យាស្ថានពាក់ព័ន្ធទៅនឹងគោលនយោបាយ យុទ្ធសាស្ត្រ ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស បញ្ហាប្រឈម និងដំណោះស្រាយ ទិសដៅ និងផែនការសកម្មភាព ក្នុងពេលខាងមុខរបស់វិទ្យាស្ថានអនុលោមតាមក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

## ៣-មុខងារតំណាង

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**

  ❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

    ▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖**

      • បានអញ្ជើញទទួលព្រះរាជដំណើរយាងនិវត្តន៍របស់ **ព្រះករុណាព្រះបាទសម្តេចព្រះ**

**បរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីពិនិត្យព្រះរាជសុខភាព នៅអាកាសយានដ្ឋានអន្តរជាតិតេជោ។

- បានអញ្ជើញដង្ហែ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតា**ជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីចម្រើនសេចក្តីសុខជូនព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។
- បានអញ្ជើញតាមដាន និងផ្តល់យោបល់លើការវិវត្តសភាពការណ៍កម្ពុជា-ថៃ និងការរៀបចំលើសេចក្តីថ្លែងការណ៍រួមស្តីពី កិច្ចព្រមព្រៀងសន្តិភាពគូឡាឡាំពួ ជាមួយរាជរដ្ឋាភិបាលព្រះរាជាណាចក្រថៃ និង
- បានអញ្ជើញចូលរួមពិធីបុណ្យរំលឹកខួបមួយឆ្នាំនៃមរណភាពរបស់ **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា នៅសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **បេសកកម្មក្នុងប្រទេស៖**
  - បានអញ្ជើញចុះជួបសំណេះសំណាលជាមួយមន្ត្រីរាជការ ប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីសភាពការណ៍ព្រំដែនកម្ពុជា ដែលមានអ្នកចូលរួមសរុប ចំនួន៤៩៣នាក់ នៅស្រុកកោះសូទិន និងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម និង
  - បានចាត់តាំងទីប្រឹក្សា និងមន្ត្រីជំនួយការខុទ្ទកាល័យ ចុះជួបសំណេះសំណាល និងនាំយកអំណោយដ៏ថ្លៃថ្លាជាសម្ភារប្រើប្រាស់ចាំបាច់មួយចំនួនរបស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា** ចែកជូនដល់វីរកងទ័ពជួរមុខ នៃកងពលតូចអន្តរាគមន៍ទី១ យោធភូមិភាគទី៤ និងយោធភូមិភាគទី៥ នៅខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងយោធភូមិភាគទី៤ ខេត្តបាត់ដំបង។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញទទួលព្រះរាជដំណើរយាងនិវត្តន៍របស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីពិនិត្យព្រះរាជសុខភាព នៅអាកាសយានដ្ឋានអន្តរជាតិតេជោ។
  - បានអញ្ជើញចូលរួម "មហាសន្និបាតវិសាមញ្ញតំណាងសមាគមអតីតយុទ្ធជនទូទាំងប្រទេសកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ និង
  - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព និងអញ្ជើញជា

គណៈអធិបតីក្នុងពិធីបូជាសព **ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ មាឃ ផល** ម្ដាយក្មេករបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា នៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខឿ្សនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែ ជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីបូកសរុបលទ្ធផលការងារ នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ដើម្បីពិនិត្យ និងពិភាក្សាអំពីវឌ្ឍនភាពការងាររបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញដឹកនាំប្រជុំពិភាក្សាលើរបាយការណ៍របស់គណៈកម្មការទី២ស្ដីពី "សាធនភាព" ដោយមានការចូលរួមពីគណៈកម្មការទី២ គណៈកម្មការទី៦ និង គណៈកម្មការទី៩ នៅវិមានព្រឹទ្ធសភា និង
  - បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយទីប្រឹក្សា ថ្នាក់ដឹកនាំ និងសមាជិកខុទ្ទកាល័យ ប្រចាំខែតុលា និងកំណត់ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- **សកម្មភាពចុះមូលដ្ឋាន៖** បានចាត់តំណាងប្រគល់អង្ករ ចំនួន៥០បាវ និងទឹកសុទ្ធ ចំនួន៥០កេស ជូនដល់វីរកងទ័ពជួរមុខ តាមរយៈ **លោកជំទាវ មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ព្រមទាំងបានផ្ដល់អង្ករ ចំនួន៥០បាវ សម្រាប់ចែកជូនសាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ " ព្រះបរមរតនកោដ្ឋ "** នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។
  - បានអញ្ជើញចូលរួមពិធីបុណ្យកឋិនទានដង្ហែទៅវេរប្រគេនចំពោះព្រះភិក្ខុសង្ឃ ដែលគង់ចាំព្រះវស្សាអស់ត្រីមាស ក្នុងពុទ្ធសីមាវត្តនាគវ័ន នៅអង្គភាពប្រឆាំងអំពើពុករលួយ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
  - បានអញ្ជើញដឹកនាំគណៈប្រតិភូក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ មាឃ ផល** ម្ដាយក្មេករបស់

**ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា នៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប៧ថ្ងៃ ដើម្បីឧទ្ទិសមហាកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធ **ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ មាយ ផល** ម្ដាយក្មេករបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា នៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងពិធីបុណ្យរំលឹកខួបមួយឆ្នាំនៃមរណភាពរបស់ **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា នៅសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃ និង១០០ថ្ងៃ ដើម្បីឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធ **លោកជំទាវបណ្ឌិត អ៊ូ រ៉ាវី** អតីតរដ្ឋលេខាធិការ និងជាទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៧ថ្ងៃ និង១០០ថ្ងៃ ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធសព **មហាឧបាសិកា អ៊ុច បូ** ម្ដាយក្មេករបស់ **ឯកឧត្តម ងួន សុជាតិ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម នៅសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុង "មហាសន្និបាតវិសាមញ្ញតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ ប្រធានព្រឹទ្ធសភា និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា នៅទីស្ដីការក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមកិច្ចប្រជុំដើម្បីបូកសរុបលទ្ធផលការងារចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ នីតិកាលទី៥ របស់គណៈកម្មការទាំង១០ សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ភាពធន់នៃសេដ្ឋកិច្ច និងការជំនួសការនាំចូល" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈាង វុន** ប្រធានគណៈកម្មការទី២រដ្ឋសភា នៅវិមានរដ្ឋសភា។
- បានអញ្ជើញទស្សនកិច្ចសិក្សាឈ្វេងយល់ក្រុមហ៊ុន អេអាយ ហ្វាម (AI FARM ROBOTICS) នៅខណ្ឌដង្កោ រាជធានីភ្នំពេញ។
- បានអញ្ជើញថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ " ព្រះបរមរតនកោដ្ឋ "** នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា (AMH) ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅខណ្ឌឫស្សីកែវ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និងសាលាស្រុកពាមជរ ខេត្តព្រៃវែង និងនៅមន្ទីរបង្អែកស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
- បានអញ្ជើញជួបពិភាក្សាការងារជាមួយសមាគមពេទ្យព្យាបាលដោយចលនា(សពចក) ដឹកនាំដោយ **លោក ហៀម ហឿង** ប្រធានសមាគម និង**ឯកឧត្តម សុខ សំណាង** ប្រធានកិត្តិយស នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចុះទស្សនកិច្ចសិក្សាឈ្វេងយល់អាកាសយានដ្ឋានអន្តរជាតិតេជោ នៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអាកាសយានដ្ឋានអន្តរជាតិតេជោ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុនម៉ាណែត** នៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និង

- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ និងជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀននាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ សន្តិសុខ សណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា **ចំនួន១៣២លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១៣៦លើក**។

**- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមព្រះរាជពិធីចម្រើនសេចក្ដីសុខជូនព្រះរាជាណាចក្រកម្ពុជា ដោយមានការយាងចូលរួមពី **សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង និង
- បានអញ្ជើញសួរសុខទុក្ខ **ឯកឧត្តម ប៊ុន សំបូរ** ដែលបំពេញការងារនៅខុទ្ទកាល័យសម្ដេចតេជោប្រធានព្រឹទ្ធសភា និងជារដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី ដែលសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញគោរពជូនពរ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ក្នុងឱកាសចម្រើនជន្មាយុ នៅបន្ទប់ទទួលភ្ញៀវឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា។

- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។

- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាៈ
  - បានអញ្ជើញចូលរួមពិធីបុណ្យទក្ខិណានុប្បទាន គម្រប់ខួប១ឆ្នាំ និងពិធីបុណ្យឆ្លងចេតិយឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធ **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា នៅគេហដ្ឋាន សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
  - បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន១១លើក។

- **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាៈ
  - តំណាងឱ្យ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញនាំយកបច្ច័យចំនួន២,០០០,០០០រៀល ទៅប្រគេនព្រះចៅអធិការវត្តបុទុមគង្គា ក្នុងឱកាសបុណ្យកឋិនទាន នៅសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។
  - បានអញ្ជើញចូលរួមប្រជុំពិភាក្សាអំពីភារកិច្ច ត្រៀមលក្ខណៈរៀបចំខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និង
  - បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៦លើក។

- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាៈ
  - បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា (AMH) ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតយកថ្លៃ នៅវត្តវារិន្ទព្រែកលៀប និងវត្តបុទុមគង្គា សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
  - បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងចូលរួមពិធីផ្សេងៗ ចំនួន៣លើក។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រាបបង្គំទូលថ្វាយព្រះពរ ក្នុងព្រះរាជវរោកាសដ៏មហានក្ខត្តឫក្សនៃព្រះរាជពិធីខួបលើកទី២១ ការយាងគ្រងព្រះបរមសិរីរាជសម្បត្តិរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា គោរពជូន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលសម្តេចមហាបវរធិបតី ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ក្នុងបុព្វហេតុស្វែងរកសន្តិភាព រហូតសម្រេចបានលទ្ធផលជោគជ័យជូនជាតិមាតុភូមិ តាមរយៈការចុះហត្ថលេខាលើ "សេចក្តីថ្លែងការណ៍រួមស្តីពី កិច្ចព្រមព្រៀងសន្តិភាពគូឡាឡាំពួ" ជាមួយរាជរដ្ឋាភិបាលព្រះរាជាណាចក្រថៃ។
- បានសហការរៀបចំពិធីបុណ្យសព ពិធីបូជាសព និងពិធីបុណ្យ៧ថ្ងៃនៃមរណភាពរបស់ **ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ មាយ ផល** ម្តាយក្មេករបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង
- បានទទួលពាក្យបណ្តឹង ចំនួន៧បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៧បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន៦បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន២បណ្តឹង ធ្វើលិខិតរំលឹកជំរុញការដោះស្រាយ ចំនួន២បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន១១បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន៨បណ្តឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**
  - ❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**
    - ▪ **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានទទួលជួបពិភាក្សាការងារ និងអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា និងវិមាន៧មករា ចំនួន៦លើក រួមមាន៖
      - \+ **បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖** បានអនុញ្ញាតឱ្យ **លោក សេង សំអុន** ប្រធានគណៈកម្មាធិការសាខាបក្សប្រចាំរដ្ឋអូរីហ្គិន និងក្រុមការងារ **លោក ម៉ក់ ហឹន** សម្របសម្រួលដោយ**ឧកញ៉ា ស្រី ចាន់ថន** អនុប្រធានតំបន់ឆ្នេរខាងលិចនៃសហរដ្ឋអាមេរិក ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។
      - \+ **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានទទួលជួបពិភាក្សាការងារ និងអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម ចំនួន៥លើក រួមមាន៖

        ១/ **ឯកឧត្តមបណ្ឌិត** Roosevelt Skerrit នាយករដ្ឋមន្ត្រីកុំមិនវែលដូមីនីក។

        ២/ **ឯកឧត្តម** Datuk Wira Dr. Mohd Hatta bin Md Ramli សមាជិកព្រឹទ្ធសភាសហព័ន្ធម៉ាឡេស៊ី។

        ៣/ **ឯកឧត្តម** Dato Seri' Ahmad Zahid bin Hamidi ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍តំបន់ និងជនបទនៃសហព័ន្ធម៉ាឡេស៊ី។

៤/ **ឯកឧត្តម TANAKA Akihiko** ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) និង

៥/ **ឯកឧត្តម Tan Sri Michael Yeoh** ប្រធានវិទ្យាស្ថានយុទ្ធសាស្ត្រ KSI ប្រចាំតំបន់អាស៊ី ប៉ាស៊ីហ្វិក។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖** បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមលក្ខណៈចូលរួមមហាសន្និបាត លើកទី១៥១ នៃសហភាពអន្តរសភា (IPU-151th) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។
- **បេសកកម្មក្រៅប្រទេស៖**
  - បានអញ្ជើញចូលរួមសន្និសីទគ្រឿងបរិក្ខារសមុទ្រពិភពលោកឆ្នាំ២០២៥ ក្រោមមូលបទ "នាំក្តីសុបិន្តរបស់មនុស្សជាតិឆ្ពោះទៅកាន់អនាគតថ្មី" នៅទីក្រុងហ្វូចូវ ខេត្តហ្វូចៀន សាធារណរដ្ឋប្រជាមានិតចិន និង
  - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU-151th) និងកិច្ចប្រជុំពាក់ព័ន្ធនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និង**ឯកឧត្តមបណ្ឌិត ឆន់ ខន្ធរ៉ា** អនុប្រធានទី២ព្រឹទ្ធសភា ព្រមទាំងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី៧៦ឆ្នាំនៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន ដែលរៀបចំឡើងដោយស្ថានទូតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធរ៉ា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានទទួលជួបពិភាក្សាការងារ និងអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ ចូលជួបសម្តែងការគួរសម នៅសាលពិសេស៣ វិមានព្រឹទ្ធសភា ចំនួន៤លើក រួមមាន៖

  + **បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖** បានទទួលជួបពិភាក្សាការងារ និងអនុញ្ញាតឱ្យភ្ញៀវជាតិចូលជួបសម្តែងការគួរសម ចំនួន៣លើក រួមមាន៖

    ១/ បានអញ្ជើញជួបពិភាក្សាការងារ និងជួយសម្របសម្រួលឱ្យវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងក្រុមហ៊ុនស្មាត ធ្វើការជាមួយគ្នា ដើម្បីជំរុញការសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលជំនាញកសិកម្មផ្សារភ្ជាប់នឹងបច្ចេកវិទ្យា។

    ២/ បានជួបពិភាក្សាការងារ និងសម្របសម្រួលឱ្យសមាគមកាហ្វេកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ក្រុមហ៊ុន នីលីដា និងអង្គការ CAPRED ធ្វើការជាមួយគ្នាដើម្បីជំរុញការផលិត និងការកែច្នៃកាហ្វេក្នុងស្រុកបន្ថែមសម្រាប់ផ្គត់ផ្គង់ទីផ្សារ និង

    ៣/ បានអនុញ្ញាតឱ្យស្ថាប័នហិរញ្ញវត្ថុ (ARDB, AMRET, AMK, CAMMA) សមាគមកាហ្វេកម្ពុជា និងក្រុមហ៊ុន Limsa Development Group ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

+ **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានទទួលជួបពិភាក្សាការងារជាមួយ **លោកជំទាវ** Flerida Ann Camille P.Mayo ឯកអគ្គរដ្ឋទូតហ្វីលីពីន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យសភា កសិកម្ម អប់រំ ពាណិជ្ជកម្ម និងបច្ចេកវិទ្យា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញចូលរួមពិធីទទួលទានអាហារល្ងាច រៀបចំដោយ **ឯកឧត្តម** UENO Atsushi ឯកអគ្គរដ្ឋទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រឹងចំណងមិត្តភាពកម្ពុជា-ជប៉ុន ឱ្យកាន់តែស៊ីជម្រៅ នៅស្ថានឯកអគ្គរដ្ឋទូតជប៉ុន រាជធានីភ្នំពេញ និង
  - បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី៦៨នៃថ្ងៃបុណ្យជាតិប្រទេសម៉ាឡេស៊ី នៅសណ្ឋាគារ Shangri-La Phnom Penh។

❖ **ឯកឧត្តម យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមសន្និសីទសមាជិកសភាស្តីពី ការអប់រំសម្រាប់ជីវិត សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។

❖ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយក្រុមអ្នកវិនិយោគទុនមកពីសាធារណរដ្ឋសង្គមនិយមវៀតណាម នៅខេត្តកំពង់ស្ពឺ។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឡា៉** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញទទួលជួប **លោកឧកញ៉ា ឌិន សុមេធារិទ្ធ** ប្រធានសហព័ន្ធទេសចរណ៍កម្ពុជា និង**លោក** Jean Paul Vogels នៅគណៈកម្មការទី៥ វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយ **ឯកឧត្តម គីម ប្យុងជោ** សមាជិករដ្ឋសភានៃសាធារណរដ្ឋកូរ៉េ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និង**ឯកឧត្តមបណ្ឌិត ចែម វីឡា៉** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីជប់លៀង តបតាមការអញ្ជើញរបស់ **លោក** Tony Peck ប្រធានក្រុមអនុព័ន្ធការពារជាតិអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា និង **លោក** Dean Uren មេបញ្ជាការកប៉ាល់ HMAS Ballarat នៅលើនាវាកងទ័ពជើងទឹករបស់អូស្ត្រាលី ខេត្តព្រះសីហនុ។

❖ **ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីជប់លៀងអបអរសាទរទិវាបុណ្យជាតិ និងខួបលើកទី៧៧ របស់កងទ័ពនៃសាធារណរដ្ឋកូរ៉េ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឡា៉** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា **ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និង**ឯកឧត្តម សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យជាតិអាល្លឺម៉ង់ លើកទី៣៥ នៅសណ្ឋាគារ Rosewood រាជធានីភ្នំពេញ ។

- **ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានយាងចូលរួមសន្និសីទក្រោមមូលបទ "រួមគ្នាដើម្បីភាពធន់អាកាសធាតុ" នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ។

**- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
  - បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសម ពិភាក្សាការងារ ជាមួយភ្ញៀវអន្តរជាតិ ចំនួន៥លើក។
  - បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ក្នុងជំនួបពិភាក្សាការងារ មហាសន្និបាត និងកិច្ចប្រជុំ ចំនួន៣លើក។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមលក្ខណៈចូលរួមមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU-151st) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដឹកនាំដោយ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានគណៈប្រតិភូ។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភា( ASGP ) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។
  - បានអញ្ជើញចូលរួមកម្មវិធីអបអរសាទរការចូលជាសមាជិកទី១១ របស់អាស៊ាននៃសាធារណរដ្ឋទីម័រឡេស្តេ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រី ប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារហៃយ៉ាត់រីជិនស៊ីភ្នំពេញ។
  - បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ ចំនួន២លើក រួមមាន៖
    - **ឯកឧត្តម Kyaw Soe Min** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការនានា ដែលជាផលប្រយោជន៍រួមរវាងស្ថាប័នទាំងពីរ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា និង
    - អគ្គលេខាធិការម៉ារ៉ុក, តំណាងអគ្គលេខាធិការនៃសភាបារាំង, អគ្គលេខាធិការសភាទីម័រឡេស្តេ និងអគ្គលេខាធិការរងរដ្ឋសភាវៀតណាម ដោយបានលើកឡើងអំពីកិច្ចការងារពង្រឹងសភា ក្នុងអំឡុងនៃកិច្ចប្រជុំសមាគមអគ្គលេខាធិការសភា (ASGP) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

- **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជូន និងទទួលដំណើររបស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមមហាសន្និបាតលើកទី១៥១នៃសហភាពអន្តរសភា (IPU-151st) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅអាកាសយានដ្ឋានអន្តរជាតិតេជោ និង

- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជូនដំណើររបស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា

ចូលរួមវេទិការប្បធម៌សុខដុមនីយកម្មពិភពលោក ឆ្នាំ២០២៥ នៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិតេជោ។

- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន ស្ថានទូតឥណ្ឌា មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ (CFRD) បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) បណ្ណសារដ្ឋានជាតិ-អន្តរជាតិ និងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេសនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
    - បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
    - បានអញ្ជើញដឹកនាំកិច្ចប្រជុំស្តីពី ការរៀបចំសិក្ខាសាលាស្តីពី បញ្ញាសិប្បនិម្មិត (AI) និងកិច្ចការពាក់ព័ន្ធផ្សេងៗ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា។
    - បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយនិវត្តជន និងមន្ត្រីវ័យចំណាស់របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិលើកទី២៧ ១តុលា ឆ្នាំ២០២៥ ក្រោមប្រធានបទ "វ័យចាស់ដោយសេចក្តីថ្លៃថ្នូរ" នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
    - បានអញ្ជើញចុះពិនិត្យមើលស្ថានភាពអគារ និងបរិវេណអគារក្រហម ដែលទាមទារឱ្យមានការជួសជុលជំបូលអគារ កម្រាលថ្មម៉ាប និងបេតុងកន្លែងមួយចំនួនមានបញ្ហាជ្រាបទឹក និងប្រេះបែក។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានអញ្ជើញជាគណៈអធិបតីនៃពិធីក្រុងពាលីបើកការដ្ឋានសាងសង់គម្រោងប្រព័ន្ធរំដោះទឹកក្នុងបរិវេណព្រឹទ្ធសភា។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាអនុប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណា** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា ព្រមទាំងក្រុមការងារបច្ចេកទេសសាងសង់អគារថ្មីនៃព្រឹទ្ធសភា បានអញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចដំណើរការពិនិត្យ និងរៀបចំបែបបទវាយតម្លៃសមត្ថភាពបុគ្គលិកជាប់កិច្ចសន្យា និងបន្តកិច្ចសន្យាការងារដល់បុគ្គលិកជាប់កិច្ចសន្យា នៅគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលពិសេសកណ្តាល វិមានព្រឹទ្ធសភា។
- **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើ "សេចក្តីព្រាងអនុក្រឹត្យស្តីពី ការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្មថ្នាក់ជាតិ" នៅសណ្ឋាគារសុខាភ្នំពេញ និង
- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។

**៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**

- បានរៀបចំអាណត្តិទូទាត់សោហ៊ុយទូរសព្ទ និងថ្លៃប្រើប្រាស់សេវាប្រៃសណីយ៍របស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- បានបង្វែរប្រាក់បង់វិភាគទានហានិភ័យការងារ និងភាគទានថែទាំសុខភាព ជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៥។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែតុលា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែតុលា ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៩៨សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន១២៤សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៦សំណើ។
- បានថតចម្លងឯកសារ ចំនួន១,៩២៥ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន២៣,៧៩៤សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ១២៦លើក ស្មើនឹង៣២៤នាក់។

- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្ដល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៤១លើក។
- បានទទួលលិខិតចូល ចំនួន៣៦៩ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៤០៣ច្បាប់។
- បានរៀបចំធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២៤ច្បាប់ ស្មើនឹង៩៤នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកា ព្រឹទ្ធសភា ចំនួន៩ច្បាប់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
  - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១២លើក។
  - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា ចំនួន២លើក និង
  - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានបន្តសម្របសម្រួលការរៀបចំគូប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេសវិមានព្រឹទ្ធសភា។
- បានរៀបចំធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា មានចំនួន ៧២១នាក់(ស្រី២៩២នាក់) ក្នុងនោះ
  - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់។
  - មន្ត្រីរាជការស្ថិតនៅក្រៅក្របខណ្ឌដើម ចំនួន៥នាក់។
  - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៦នាក់ និង
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៩២នាក់ (ស្រី៣៦នាក់)។
- បានរៀបចំធ្វើសេចក្ដីសម្រេច ចំនួន២ច្បាប់ និងលិខិតបង្គាប់ការ ចំនួន១ច្បាប់។
- បានរៀបចំធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៤ច្បាប់។
- បានរៀបចំធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែតុលាឆ្នាំ២០២៥។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី "គំនិតផ្ដួចផ្ដើមអរិយធម៌សកល និងវប្បធម៌ HeHe" របស់សាធារណរដ្ឋប្រជាមានិតចិន នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២នាក់ ចូលរួមវគ្គបណ្ដុះបណ្ដាលនៅក្រៅប្រទេសចំនួន១វគ្គ ស្ដីពី សន្តិសុខសាយប័រក្នុងសេដ្ឋកិច្ចឌីជីថលការការពារទ្រព្យសម្បត្តិឌីជីថល និងការជានាភាពទុកចិត្តក្នុងអន្តរកម្មឌីជីថល នៅប្រទេសម៉ាឡេស៊ី។
- បានបើកវគ្គបណ្ដុះបណ្ដាលក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន២វគ្គ មានសិក្ខាកាមចូលរួម ចំនួន ៦៤នាក់ រួមមាន៖
  - វគ្គ "កំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចល្អ" និង
  - វគ្គ "ជំនាញវិភាគ និងដោះស្រាយបញ្ហា"។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៧នាក់ ចូលរួមវគ្គបណ្ដុះបណ្ដាលនៅក្រៅស្ថាប័នព្រឹទ្ធសភា ចំនួន២វគ្គ រួមមាន៖ វគ្គជំនាញឌីជីថលចាំបាច់ DSE-F031 និងវគ្គជំនាញ

ឱជីថលចាំបាច់ DSE-B064 នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថល។

- ការងារជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
  - បានអ៊ុតកៅស៊ូការពារជ្រាបទឹក និងប្តូរសន្លឹកទ្វារបន្ទប់ទឹកសាធារណៈ នៅអគារខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា។
  - បានប្តូរជ្រើម៉ាបបង្អួច នៅអគារសជាន់ទី១។
  - បានដំឡើងផ្ទាំងរូបភាពក្នុងកម្មវិធី **សម្តេចតេជោប្រធានព្រឹទ្ធសភា** ជួបភ្ញៀវអន្តរជាតិ និងប្តូរផ្ទាំងរូបភាពនៅសាលប្រជុំពេញអង្គ។
  - បានប្តូរអ្នូតធំទ្វារអាលុយមីញ៉ូម នៅសាលសិក្ខាសាលាខាងជើង។
  - បានបាញ់ថ្នាំសោទ្វារ នៅអគារស ចំនួន២៧គ្រឿង។
  - បានបំពាក់ឆត្រ តុ និងកៅអីសម្រាប់នគរបាលការពារច្រកចេញ-ចូល P2 ចំនួន៥គ្រឿង និង
  - បានបោសសម្អាតដំបូលអគារនានាក្នុងបរិវេណព្រឹទ្ធសភា។
- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្តកំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិមប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៩៩គ្រឿង/លើក។
- បានរៀបចំធ្វើស្លាកលេខរថយន្តព្រឹទ្ធសភាថ្មី ជូនសមាជិកព្រឹទ្ធសភា ចំនួន១គ្រឿង។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្តាហ៍ម្តង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានបន្តស្រាវជ្រាវ និងរៀបចំសរសេរចងក្រងសៀវភៅអំពីប្រវត្តិ និងការប្រើប្រាស់អគារមួយចំនួននៅវិមានព្រឹទ្ធសភា។
- បានរៀបចំធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់សម័យប្រជុំលើកទី៣ និងលើកទី៤ នីតិកាលទី៥។
- បានរៀបចំធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា។
- បានរៀបចំធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែតុលា ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួងស្ថាប័នពាក់ព័ន្ធនានា និង
- បានរៀបចំធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៥។

**៤.៣-ការងារសេវាច្បាប់៖**

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន២៦ច្បាប់ ពីក្រសួង ស្ថាប័ននានា។

- បានរៀបចំឯកសារជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥ ជូន៖
    - ថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន៥លើក។
    - លេខាធិការសម័យប្រជុំព្រឹទ្ធសភា ចំនួន២លើក និង
    - ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤លើក។
- បានរៀបចំធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន៦លើក។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និងរៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៥១លើក។
- បានប្រមូលរៀបចំរបាយការណ៍សង្ខេបអំពីការប្រឆាំងអំពើពុករលួយ ជូនថ្នាក់ដឹកនាំក្រុមជនបង្គោល ចំនួន២អត្ថបទ។
- បានផ្ទៀងផ្ទាត់ និងសម្រួលរៀបចំបែបបទបន្តនីតិវិធីប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប ចំនួន១នាក់ និង
- បានប្រមូល និងតាមដានព័ត៌មានពាក់ព័ន្ធអំពើពុករលួយជាតិ-អន្តរជាតិ ដើម្បីផ្សព្វផ្សាយផ្ទៃក្នុង និងរក្សាទុកជាជំនួយស្មារតីជូនថ្នាក់ដឹកនាំ ចំនួន៣អត្ថបទ។

### ៥.៤-ការងារស្រាវជ្រាវ៖

- បានរៀបចំឯកសារស្រាវជ្រាវ និងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់។
- បានសរសេរបទអន្តរាគមន៍សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីក្របខណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន។
- បានរៀបចំធ្វើបទបង្ហាញលើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់ ជូនក្រុមសមាជិកព្រឹទ្ធសភាក្រុមទី៤ នៅបន្ទប់ប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។
- បានសិក្សាស្រាវជ្រាវ៖
    - ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា។
    - ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងបំណុលសាធារណៈប្រចាំឆមាសទី១ ឆ្នាំ២០២៥ និង
    - របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។
- បានសិក្សាស្រាវជ្រាវ និងតាមដាន៖
    - យុទ្ធសាស្ត្រស្តីពី ការគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០២៤-២០២៨។
    - របាយការណ៍ និន្នាការសេដ្ឋកិច្ច-សង្គម ប្រចាំខែរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
    - វឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។
    - យុទ្ធសាស្ត្រជាតិស្តីពី ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ និង

- ថវិការដ្ឋ ថវិកាថ្នាក់ក្រោមជាតិ តុល្យការថវិកា ការខ្ចី និងស្ថានភាពបំណុលសាធារណៈ និងហានិភ័យសារពើពន្ធ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ការប្រៀបធៀបបរិបទប្រទេសនៅក្នុងតំបន់អាស៊ាន។

- បានតាមដានការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៦ និងការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៤។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍នៃខែតុលា ឆ្នាំ២០២៥ ចំនួន៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន២០៩ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៤៣-៤៧ ឆ្នាំ២០២៤)។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន១៨លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន១,៧២៩លើក។
- បានបញ្ចូល និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២៩៦លើក។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន២លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខាងមុខព្រឹទ្ធសភា ចំនួន ១០លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មានស្តីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន ២២ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន៩៧គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៧២លើក។

- បានទទួលឯកសារ ទស្សនាវដ្ដី សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន១៩ក្បាល ព្រមទាំងបានដាក់លេខកូដសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី-សងសៀវភៅ ចំនួន៤ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៦៨៣ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០៣០នាក់ (ដោយគិតចាប់ពីខែមករា ឆ្នាំ២០២០ ដល់ខែតុលា ឆ្នាំ២០២៥) និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ចែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ទួន) ឆ្នាំ២០១៤ ចំនួន៥៤៥ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន៥៤សំណុំ។

### ៥.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៥៦លើក។
- បានរៀបចំសារលិខិតថ្វាយព្រះពរ លិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងលិខិតរំលែកទុក្ខ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និងគោរពជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ព្រមទាំងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ចំនួន១៤លិខិត។
- បានរៀបចំលិខិតឆ្លើយតប កំណត់ទូត និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៨ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែតុលា ឆ្នាំ២០២៥ ចំនួន ១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៩ច្បាប់។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនួយការគណៈកម្មការព្រឹទ្ធសភា ចំនួន៤រូប និង
- បានរៀបចំឯកសារជំនួយស្មារតីស្តីពី ជម្លោះព្រំដែនគោករវាងកម្ពុជា-ថៃ។

### ៥.៧-ការងារអគ្គាធិការដ្ឋាន៖

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែតុលា ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែតុលា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៤២លើក ប្រចាំសប្តាហ៍ ចំនួន ៤លើក និងប្រចាំខែតុលា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបើកសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់ រួមមានៈ
  - ១- សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៦។
  - ២- សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។
  - ៣- សេចក្តីព្រាងច្បាប់ស្តីពី កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។
  - ៤- សេចក្តីព្រាងច្បាប់ស្តីពី កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីនស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ និង
  - ៥- សេចក្តីព្រាងច្បាប់ស្តីពី ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។
- ត្រៀមរៀបចំកិច្ចប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

## ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍ នៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ឆ្នាំ២០២៥ និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និងនិស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្ដល់សេវាការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំជូនគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចការងារ នៅអគ្គលេខាធិការដ្ឋាន AIPA ទីក្រុងហ្សាការតា សាធារណរដ្ឋឥណ្ឌូណេស៊ី និង
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិ ជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមបើកវគ្គបណ្ដុះបណ្ដាលស្ដីពី ការរៀបចំតាក់តែងលិខិតរដ្ឋបាល និងកិច្ចការលេខាធិការ និងវគ្គស្ដីពី វិធីសាស្ត្រសរសេរសុន្ទរកថា បទអន្តរាគមន៍ សេចក្ដីថ្លែងការណ៍ និងជំនួយស្មារតី។
- ត្រៀមចូលរួមសិក្ខាសាលាស្ដីពី ប្រតិបត្តិកវិស័យអប់រំ និងមន្ត្រីរាជការវ័យក្មេងឆ្នាំ២០២៥ នៅសាធារណរដ្ឋប្រជាមានិតចិន។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថានអនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្ដល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្ដីសន្និដ្ឋាន

ខែតុលា ជាខែនៃការចាប់ផ្ដើមសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារស្ទួលរបស់ខ្លួន ដោយបានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន៤លើក និងបើកសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក ដើម្បីស្ដាប់របាយការណ៍សង្ខេបស្ដីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំ និងពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ចំនួន៥ច្បាប់។

ចំពោះការងារការទូតសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្មក្នុងការរៀបចំបដិសណ្ឋារកិច្ច និងជំនួបសវនាការ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយឥស្សរជននយោបាយជាន់ខ្ពស់នានា មកបំពេញទស្សនកិច្ចនៅកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរ។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋាន ក៏បានផ្ដល់សេវាលើមុខងារតំណាងជូន សមាជិក សមាជិកាព្រឹទ្ធសភា ចុះជួបពិភាក្សាការងារ និងប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គបោះឆ្នោតទទួលបានលទ្ធផលគួរជាទីមោទនៈ ដែលជាគុណប្រយោជន៍រួមសម្រាប់ស្ថាប័ន និងប្រជាជន។

ក្រៅពីបំពេញមុខងារស្ទួលរបស់ខ្លួន ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបន្តសកម្មភាពការងាររួមចំណែកទ្រទ្រង់សមរភូមិមុខតាមរយៈការនាំយកអំណោយស្បៀងអាហារ សម្ភារប្រើប្រាស់ជូនកងទ័ព និងប្រជាពលរដ្ឋភៀសសឹក នៅតាមបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។

ថ្ងៃអង្គារ ១១កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្ដស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**